# សំណូមពរ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ចំពោះរាជរដ្ឋាភិបាលខ្មែរ សូមសើរើពិនិត្យឡើងវិញ នូវបង្គោលព្រំដែនកម្ពុជា-វៀតណាមដែលបាន បោះក្នុងអំឡុងឆ្នាំ១៩៨០

web site: hoksavann.org

ថ្ងៃទី២៣ កុម្ភៈ ២០០៦

កាលពីថ្ងៃទី១៥ កុម្ភៈ ២០០៦ អាត្មាបានសុំព្រះរាជទានអន្តរាគមន៍ ពីព្រះមហាក្សត្រខ្មែរ ទៅរាជរដ្ឋាភិបាលកម្ពុជា សុំអាជ្ញាធរខ្មែរទទួលបន្ទុកព្រំដែនកម្ពុជា រួមប្រជុំជាមួយអ្នកបច្ចេកទេសព្រំដែនខាងក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាព្រំដែន និងសុំបង្កើតក្រសួងអន្តោប្រវេសន៍ ។

ឥឡូវនេះ តាមដំណឹងថា លោកនាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាម នឹងមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅដើមខែមីនានេះ ក្នុងគោលបំណងពិភាក្សាជាមួយភាគីខ្មែរ ដើម្បីបោះបង្គោលព្រំដែនកម្ពុជា-វៀតណាម ដែលនៅសេសសល់ឲ្យរួចស្រេចក្នុងបំណាច់ឆ្នាំ២០០៦នេះ ។

ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស មានមន្ទិលសង្ស័យ និងមានការព្រួយបារម្ភជាខ្លាំង អំពីការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាមអំឡុងឆ្នាំ១៩៨០ គឺបោះនៅពេលដែលមានភាពពុំស្មើគ្នា ដោយពេលនោះវៀតណាមត្រួតត្រាប្រទេសកម្ពុជាដោយកម្លាំងទ័ព ។ ដូច្នេះការបោះបង្គោលនោះ ក៏គ្មានភាពត្រឹមត្រូវដែរ ដែលខ្មែរអាចបាត់បង់ទឹកដីរបស់ខ្លួន ។

យោលតាមការព្រួយបារម្ភនេះហើយ សូមធ្វើសំណូមពរដល់រាជរដ្ឋាភិបាលខ្មែរ មុននឹងសំរេចបោះបង្គោលព្រំដែនកម្ពុជា-វៀតណាមជាបន្តទៅទៀត សូមអាជ្ញាធររាជរដ្ឋាភិបាលទទួលបន្ទុកព្រំដែនកម្ពុជា រួមប្រជុំពិភាក្សាជាមួយអ្នកបច្ចេកទេសព្រំដែនកម្ពុជា អង្គការក្រៅរដ្ឋាភិបាល សើរើពិនិត្យឡើងវិញ នូវបង្គោលព្រំដែនកម្ពុជា-វៀតណាម ដែលបានបោះក្នុងអំឡុងឆ្នាំ១៩៨០ ដើម្បីឲ្យដឹងការពិត ជៀស

វាងការបាត់បង់ទឹកដី ដោយយកតាមផែនទីដែលអន្តរជាតិទទួលស្គាល់ ។ បើពិនិត្យទៅឃើញថា ការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាមអំឡុងឆ្នាំ១៩៨០ ពុំបានត្រឹមត្រូវទេ បានធ្វើឲ្យប្រទេសកម្ពុជាបាត់បង់ទឹកដី ត្រូវប្រាប់ភាគីវៀតណាមបង្ហាញការពិតនោះ ហើយដកបង្គោលនោះចេញ រួចបោះជាថ្មីឲ្យត្រឹមត្រូវឡើងវិញ ។

រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះ ទទួលខុសត្រូវធ្ងន់ណាស់អំពីបញ្ហាទឹកដីនេះ ត្រូវតែរួមមតិយោបល់ ដោយសហការគ្នានូវគ្រប់អង្គការខ្មែរស្នេហាទឹកដីទាំងអស់ ដើម្បីថែរក្សាមត៌ក ដែលនៅតូចនេះកុំឲ្យបាត់បង់តទៅទៀត ។

វត្តខ្មែរកាណាដា, ថ្ងៃទី២៣ កុម្ភៈ ២០០៦
ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

❑ ❑

❑